# Franklin Learning Center High School

***-A Pennsylvania Blue Ribbon School of Excellence-***
***-Middle States Association Accredited School-***

616 N. 15th Street
Philadelphia, PA 19130

***Mrs. Nicole Lee, Principal*** — ***215-400-7570,***
***Dr. LaTrina Stewart, Assistant Principal*** — ***215-400-7571 (fax)***
***Mr. Anthony Guidice, Assistant Principal***

ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

ជូនចំពោះក្រុមគ្រួសាររបស់វិទ្យាល័យ FLC៖

នៅពេលដែលយើងទុកព្រឹត្តិការណ៍កាលពីឆ្នាំទៅឲ្យនៅពីក្រោយយើង ហើយយើងបន្តទៅមុខទៀតជាមួយនឹងផែនការរបស់យើងសម្រាប់ការវិលត្រឡប់ទៅរៀននៅសាលាដោយផ្ទាល់វិញនៅឆ្នាំក្រោយ គឺជាសារៈសំខាន់ជាងពេលណាទាំងអស់ដើម្បីតភ្ជាប់ទំនាក់ទំនងជាមួយគ្នាឡើងវិញ ហើយកំណត់ឲ្យច្បាស់ថាតើមានន័យដូចម្ដេចក្នុងការចូលរួមចំណែកជាមួយសហគមន៍វិទ្យាល័យ FLC។ គ្រប់សហគមន៍ទាំងអស់ មិនថាធំ ឬតូច ដំណើរការក្រោមតម្លៃសំខាន់ៗដែលសំដៅទៅលើជំនឿរួមរបស់សហគមន៍នោះ និងបំពេញមុខងារដើម្បីកំណត់ការចង់បានសម្រាប់បទដ្ឋានសង្គម ហើយថាតើគួរប្រព្រឹត្តលើអ្នកដទៃរបៀបណា។ ជាលទ្ធផលនៃការស្រាវជ្រាវ ការទទួលស្គាល់ជាផ្លូវការរបស់រដ្ឋកណ្ដាល (Middle State Accreditation) របស់យើង វិទ្យាល័យ FLC បានឃើញនូវសេចក្ដីត្រូវការដើម្បីពិនិត្យមើលកថាថ្លែងពីគោលបំណងរបស់យើងឡើងវិញ ហើយបង្កើតគោលបំណងថ្មីដូចតទៅ៖ ***វិទ្យាល័យ FLC គឺជាសហគមន៍សាលាដែលមានការរួមបញ្ចូល ដែលបានប្ដេជ្ញាចិត្តដើម្បីផ្ដល់នូវក្រុមសិស្សចម្រុះជាមួយនឹងការឆ្លើយតបការអប់រំ និងវប្បធម៌យ៉ាងហ្មត់ចត់ ដែលត្រៀមសិស្សនូវជំនាញវិជ្ជាជីវៈ និងជំនាញសង្គម ដែលពួកគេត្រូវការដើម្បីក្លាយជាសមាជិកសហគមន៍ដ៏ឆ្នើមរបស់ ទីក្រុង ប្រទេស និងពិភពលោក។*** ក្នុងការអភិវឌ្ឍន៍គោលបំណងថ្មីនេះយើងបានកំណត់តម្លៃសំខាន់ៗទាំងបួនរបស់យើង គឺ៖ សច្ចៈធម៌ កិត្តិយស មេត្តាធម៌ និង យុត្តិធម៌។

ក្នុងកំឡុងខែកក្កដា និងខែសីហា យើងចង់រកមើលសិស្សណាដែលចាប់អារម្មណ៍ចង់ក្លាយជា **សិស្សតំណាងឲ្យសាលា** (**Student Ambassadors**) នៅវិទ្យាល័យ FLC។ សិស្សតំណាងឲ្យសាលារបស់យើងនឹងជាក្រុមដែលមានផលិតភាពខ្ពស់ ដែលប្ដេជ្ញាចិត្តបង្កើនស្មារតី មោទនភាព និងប្រពៃណីនៅវិទ្យាល័យ FLC។ សិស្សតំណាងឲ្យសាលានឹងធ្វើជាតំណាងសិស្សជាផ្លូវការរបស់វិទ្យាល័យ FLC ហើយក៏ជាអ្នកទំនាក់ទំនងជាសាធារណៈរបស់សិស្ស តំណាងឲ្យសាលានៅក្នុងព្រឹត្តិការណ៍ផ្សេងៗ។ សិស្សតំណាងឲ្យសាលានឹងខិតខំជំរុញឲ្យមានការរីកចម្រើន និងការពង្រីក នៅវិទ្យាល័យ FLC ជំរុញឲ្យមានការចូលរួមជាមួយជីវិតក្នុងបរិវេណសាលា ព្រមទាំងបញ្ចូលស្មារតី និងមោទនភាព ដោយអប់រំសហគមន៍ក្នុងបរិវេណសាលា និងអ្នកសំខាន់ៗដែលនៅខាងក្រៅ អំពីវិទ្យាល័យ FLC។ សិស្សតំណាងឲ្យសិស្សនៅវិទ្យាល័យ Franklin Learning Center នឹងជាអ្នកតំណាងរបស់សិស្សទាំងអស់ ដែលមានបទពិសោធ និងប្រវត្តិផ្សេងៗគ្នា។

ចាប់ផ្ដើមនៅខែសីហា យើងនឹងអញ្ជើញសិស្សដែលមានចំណាប់អារម្មណ៍មកជួយយើងរិះរកតម្លៃសំខាន់ៗទាំងនេះ និងកំណត់នូវអ្វីដែលពួកគេមើលទៅ និងស្ដាប់ទៅ ថាដូចជាវិទ្យាល័យ FLC ។ តាមរយៈនៃការសម្ភាសន៍ និងការពិភាក្សា តាមការជួបផ្ទាល់ និង/ឬ តាមវីដេអូ ជាបន្តបន្ទាប់ សិស្សនឹងមានឱកាសបញ្ចេញយោបល់របស់ពួកគេលើតម្លៃសំខាន់ៗរបស់យើង ហើយជួយជំរុញទស្សនៈវិស័យនៃរបៀបដែលយើងនឹងបង្កើតតម្លៃទាំងនេះ ទូទាំងសាលា នៅវិទ្យា  ល័យ FLC។ ប្រសិនបើអ្នកចង់ក្លាយជាសិស្សតំណាងឲ្យវិទ្យាល័យ FLC ចង់ធ្វើកិច្ចការនេះ ហើយចង់ចូលរួមចំណែកក្នុងការអភិវឌ្ឍន៍វប្បធម៌រួមថ្មីរបស់យើង សូមអ៊ីមែល Ms. Lee នៅ nlee@philasd.org និង Mr. Guidice នៅ amguidice@philasd.org ហើយយើងនឹងទាក់ទងទៅអ្នកដើម្បីផ្ដល់ ថ្ងៃខែ និងព័ត៌មានលម្អិត បន្ថែម។

តំណែងនេះបើកឲ្យសិស្សទាំងអស់ ទាំងសិស្សទើបនឹងចូលរៀនឆ្នាំទីមួយ!

សូមមានរដូវក្ដៅដ៏អស្ចារ្យ!

វិទ្យាល័យ FLC

**MISSION STATEMENT**

***FLC is an inclusive school community dedicated to providing a diverse student body with a rigorous and culturally-responsive education that prepares students with the professional and social skills they need to be outstanding community members of the city, nation, and world.***